**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ**
**បណ្ឌិត្យសភានគរបាលកម្ពុជា**

លេខ:..០០៣..សណ.ន

# សេចក្តីណែនាំ
## ស្តីពី
## ការវាយតម្លៃការដឹកនាំគ្រប់គ្រងនិងការបង្ហាត់បង្រៀនរបស់សាស្ត្រាចារ្យនិងគ្រូនគរបាលជាតិ នៅសាលានគរបាលជាតិភូមិភាគ និងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម នៃបណ្ឌិត្យសភានគរបាលកម្ពុជា

បណ្ឌិត្យសភានគរបាលកម្ពុជា បានដាក់ចេញនូវកម្មវិធីកំណែទម្រង់លើការងារសំខាន់ៗជាច្រើន ក្នុងនោះ ការអភិវឌ្ឍសមត្ថភាពសាស្ត្រាចារ្យនិងគ្រូនគរបាលជាតិ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការដឹកនាំគ្រប់គ្រង គុណភាពអប់រំបណ្តុះបណ្តាល និងបរិស្ថានអនាម័យរបស់សាលានគរបាលជាតិភូមិភាគ និងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម ជាកិច្ចការងារចាំបាច់នៃកំណែទម្រង់ ដែលត្រូវអនុវត្តជាអចិន្ត្រៃយ៍ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពនៃការដឹកនាំគ្រប់គង និងគុណភាពនៃការអប់រំបណ្តុះបណ្តាលនៅសាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម និងពង្រឹងសមត្ថភាពវិជ្ជាជីវៈមន្ត្រីនគរបាលជាតិ ឱ្យស្របតាមស្តង់ដាគុណភាពអប្បបរមាសម្រាប់វាយតម្លៃសាលានគរបាលជាតិភូមិភាគនិងស្តង់ដាគុណភាពសម្រាប់វាយតម្លៃគុណភាពអប់រំផ្ទៃក្នុងនៃបណ្ឌិត្យសភានគរបាលកម្ពុជា។

ក្នុងការរកឱ្យឃើញនូវចំណុចខ្លាំងនិងចំណុចដែលត្រូវកែលម្អលើការដឹកនាំគ្រប់គ្រង និងការបង្ហាត់បង្រៀនរបស់សាស្ត្រាចារ្យនិងគ្រូនគរបាលជាតិ នៅសាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម បណ្ឌិត្យសភានគរបាលកម្ពុជា បានបង្កើតឱ្យមានកម្រងសំណួរវាយតម្លៃការដឹកនាំគ្រប់គ្រង និងបង្ហាត់បង្រៀននៅតាមសាលានគរបាលជាតិ ដែលមានចំនួន ៤ទម្រង់ដាច់ដោយឡែកពីគ្នាដូចខាងក្រោម៖

១- កម្រងសំណួរវាយតម្លៃការដឹកនាំគ្រប់គ្រង និងការបង្ហាត់បង្រៀន នៅសាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម ដោយសិក្ខាកាមនិងសិស្សនគរបាលជាតិ។

២- កម្រងសំណួរវាយតម្លៃការដឹកនាំគ្រប់គ្រងសាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម ដោយក្រុមការងារចុះវាយតម្លៃ។

៣- កម្រងសំណួរវាយតម្លៃការដឹកនាំគ្រប់គ្រងសាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម ដោយសាស្ត្រាចារ្យនិងគ្រូនគរបាលជាតិ។

៤- កម្រងសំណួរវាយតម្លៃការដឹកនាំគ្រប់គ្រងសាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម ដោយមន្ត្រីសាលា។

ដើម្បីឱ្យការវាយតម្លៃការដឹកនាំគ្រប់គ្រង និងការបង្ហាត់បង្រៀនរបស់សាស្ត្រាចារ្យនិងគ្រូនគរបាលជាតិ នៅសាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម ប្រព្រឹត្តទៅដោយឯកភាពគ្នា និងកាន់តែល្អប្រសើរថែមទៀត បណ្ឌិត្យសភានគរបាលកម្ពុជា សូមធ្វើការណែនាំ ដូចតទៅៈ

**១- ការវាយតម្លៃការដឹកនាំគ្រប់គ្រងនិងការបង្ហាត់បង្រៀន នៅសាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម ដោយសិក្ខាកាមនិងសិស្សនគរបាលជាតិ**

ការវាយតម្លៃការដឹកនាំគ្រប់គ្រងរបស់សាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម និងការបង្ហាត់បង្រៀនរបស់សាស្ត្រាចារ្យនិងគ្រូនគរបាលជាតិ ដែលបានបង្ហាត់បង្រៀននៅសាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម ដោយសិក្ខាកាម និងសិស្សនគរបាលជាតិនៃវគ្គបណ្តុះបណ្តាលនីមួយៗ ដើម្បីរកឱ្យឃើញនូវចំណុចខ្លាំង និងចំណុចដែលត្រូវកែលម្អលើប្រសិទ្ធភាពនៃដឹកនាំគ្រប់គ្រង គុណភាពអប់រំបណ្តុះបណ្តាល និងបរិស្ថានអនាម័យរបស់សាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម និងគុណភាពនៃការបង្ហាត់បង្រៀនរបស់សាស្ត្រាចារ្យនិងគ្រូនគរបាលជាតិ ដែលបានបង្ហាត់បង្រៀនលើមុខវិជ្ជាឬមេរៀននៃកម្មវិធីអប់រំ ដោយប្រើកម្រងសំណួរដូចកំណត់ក្នុងឧបសម្ព័ន្ធ១។ កម្រងសំណួរនេះ ត្រូវមានភាពបត់បែន ដោយបញ្ចូលការវាយតម្លៃរាល់បាឋកថារបស់វាគ្មិន និងមុខវិជ្ជាឬមេរៀនរបស់សាស្ត្រាចារ្យនិងគ្រូនគរបាលជាតិ ដែលបានបង្ហាត់បង្រៀន និងចែករំលែកចំណេះដឹងនៃវគ្គបណ្តុះបណ្តាល ស្របតាមកម្មវិធីអប់រំដែលបានកំណត់។

**២- ការវាយតម្លៃការដឹកនាំគ្រប់គ្រងសាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម ដោយក្រុមការងារចុះវាយតម្លៃ**

ការវាយតម្លៃការដឹកនាំគ្រប់គ្រងរបស់សាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម ដោយក្រុមការងារចុះវាយតម្លៃរបស់បណ្ឌិត្យសភានគរបាលកម្ពុជា ដើម្បីរកឱ្យឃើញនូវចំណុចខ្លាំង និងចំណុចដែលត្រូវកែលម្អលើប្រសិទ្ធភាពនៃដឹកនាំគ្រប់គ្រង គុណភាពអប់រំបណ្តុះបណ្តាល និងបរិស្ថានអនាម័យរបស់សាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម ដោយប្រើកម្រងសំណួរដូចកំណត់ក្នុងឧបសម្ព័ន្ធ២។

**៣- ការវាយតម្លៃការដឹកនាំគ្រប់គ្រងសាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម ដោយសាស្ត្រាចារ្យនិងគ្រូនគរបាលជាតិ**

ការវាយតម្លៃការដឹកនាំគ្រប់គ្រងរបស់សាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម ដោយសាស្ត្រាចារ្យនិងគ្រូនគរបាលជាតិ ដើម្បីរកឱ្យឃើញនូវចំណុចខ្លាំង និងចំណុចដែលត្រូវកែលម្អលើប្រសិទ្ធភាពនៃដឹកនាំគ្រប់គ្រង គុណភាពអប់រំបណ្តុះបណ្តាល និងបរិស្ថានអនាម័យរបស់សាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម ដោយប្រើកម្រងសំណួរដូចកំណត់ក្នុងឧបសម្ព័ន្ធ៣។

**៤- ការវាយតម្លៃការដឹកនាំគ្រប់គ្រងសាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម ដោយមន្ត្រីសាលា**

ការវាយតម្លៃការដឹកនាំគ្រប់គ្រងរបស់សាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម ដោយមន្ត្រីសាលា ដើម្បីរកឱ្យឃើញនូវចំណុចខ្លាំង និងចំណុចដែលត្រូវកែលម្អលើប្រសិទ្ធភាពនៃដឹកនាំគ្រប់គ្រង គុណភាពអប់រំបណ្តុះបណ្តាល និងបរិស្ថានអនាម័យរបស់សាលានគរបាលជាតិភូមិភាគ និងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម ដោយប្រើកម្រងសំណួរដូចកំណត់ក្នុងឧបសម្ព័ន្ធ៤។

**៥- ដំណើរការវាយតម្លៃការដឹកនាំគ្រប់គ្រងសាលានិងការបង្ហាត់បង្រៀន**

បណ្ឌិត្យសភានគរបាលកម្ពុជា ដែលមានដេប៉ាតឺម៉ង់ធានាគុណភាពអប់រំផ្ទៃក្នុងជាសេនាធិការ ត្រូវរៀបចំក្រុមការងារចុះវាយតម្លៃរបស់បណ្ឌិត្យសភានគរបាលកម្ពុជា ដើម្បីចុះវាយតម្លៃការដឹកនាំគ្រប់គ្រងរបស់សាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម និងការបង្ហាត់បង្រៀនរបស់សាស្ត្រាចារ្យនិងគ្រូនគរបាលជាតិ ដែលបានបង្ហាត់បង្រៀននៅសាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាមតាមកម្រងសំណួរដែលបានកំណត់ក្នុងឧបសម្ព័ន្ធ១, ២, ៣ និង៤។ ក្រុមការងារ ត្រូវណែនាំអំពីខ្លឹមសារ ការដាក់ពិន្ទុ និងលើកទឹកចិត្តដល់អ្នកសិក្សា ក្រុមការងារចុះវាយតម្លៃសាស្ត្រាចារ្យនិងគ្រូនគរបាលជាតិ និងមន្ត្រីសាលា ឱ្យផ្តល់ព័ត៌មានពិត ដើម្បីរកឱ្យឃើញនូវចំណុចខ្លាំង និងចំណុចដែលត្រូវកែលម្អលើប្រសិទ្ធភាពនៃដឹកនាំគ្រប់គ្រង គុណភាពអប់រំបណ្តុះបណ្តាល និងបរិស្ថានអនាម័យរបស់សាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម និងគុណភាពនៃបង្ហាត់បង្រៀនរបស់សាស្ត្រាចារ្យនិងគ្រូនគរបាលជាតិ ដែលបានបង្ហាត់បង្រៀនលើមុខវិជ្ជាឬមេរៀននៃកម្មវិធីអប់រំ ឱ្យស្របតាមស្តង់ដាគុណភាពអប្បបរមាសម្រាប់វាយតម្លៃសាលានគរបាលជាតិភូមិភាគ និងស្តង់ដាគុណភាពសម្រាប់វាយតម្លៃគុណភាពអប់រំផ្ទៃក្នុងនៃបណ្ឌិត្យសភានគរបាលកម្ពុជា។

ក្រុមការងារចុះវាយតម្លៃ ត្រូវបូកសរុបលទ្ធផលវាយតម្លៃការដឹកនាំគ្រប់គ្រងរបស់សាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម និងការបង្ហាត់បង្រៀនរបស់សាស្ត្រាចារ្យនិងគ្រូនគរបាលជាតិ ព្រមទាំងប្រៀបធៀបនិងសំយោគលទ្ធផលវាយតម្លៃដោយអ្នកសិក្សា ក្រុមការងារចុះវាយតម្លៃសាស្ត្រាចារ្យនិងគ្រូនគរបាលជាតិ និងមន្ត្រីសាលា ដើម្បីធ្វើសេចក្តីសន្និដ្ឋានរួមមួយ។

លទ្ធផលដែលសំយោគរួច ត្រូវធ្វើរបាយការណ៍ជូនប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា។

លទ្ធផលនៃការវាយតម្លៃ ត្រូវបានផ្សព្វផ្សាយដល់សាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម និងសាស្ត្រាចារ្យនិងគ្រូនគរបាលជាតិ ដើម្បីធ្វើការពង្រឹង និងកែលម្អរាល់ចំណុចខ្វះខាត ដែលបានរកឃើញ។

**៦- ការពិនិត្យតាមដានលើការអនុវត្ត**

ដេប៉ាតឺម៉ង់ធានាគុណភាពអប់រំផ្ទៃក្នុង មានភារកិច្ចពិនិត្យតាមដាន លើការអនុវត្តសេចក្តីណែនាំនេះ និងការអនុវត្តរាល់បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀតរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍គ្រូនគរបាលជាតិ នាយកដ្ឋានបណ្តុះបណ្តាល សាលានគរបាលជាតិភូមិភាគ និងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម ដើម្បីធានា

បាននូវប្រសិទ្ធភាពលើការងារវាយតម្លៃការដឹកនាំគ្រប់គ្រង និងការបង្ហាត់បង្រៀនរបស់សាស្ត្រាចារ្យនិងគ្រូនគរបាលជាតិ នៅសាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម។ លទ្ធផលនៃការពិនិត្យតាមដាន ត្រូវផ្តល់ជូនទៅសាលានគរបាលជាតិភូមិភាគនិងសាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម និងសាស្ត្រាចារ្យនិងគ្រូនគរបាលជាតិសាមី ព្រមទាំងរាយការណ៍ជូនគណៈកម្មការធានាគុណភាពអប់រំផ្ទៃក្នុង ។

ទទួលបានសេចក្តីណែនាំនេះ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍គ្រូនគរបាលជាតិ ប្រធានមន្ទីរចាត់ការ នាយកវិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រនគរបាល នាយកវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈនគរបាល នាយកវិទ្យាស្ថានគ្រប់គ្រងនិងបញ្ជាដឹកនាំ នាយកវិទ្យាស្ថានព័ត៌មានវិទ្យានិងភាសាបរទេស ប្រធាននាយកដ្ឋានបណ្តុះបណ្តាល នាយកសាលាមធ្យមវិជ្ជាជីវៈនគរបាល ប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមន្ត្រីពន្ធនាគារ នាយកសាលាមធ្យមបច្ចេកទេស នាយកវិទ្យាស្ថានក្រោយបរិញ្ញាបត្រ ប្រធានដេប៉ាតឺម៉ង់ធានាគុណភាពអប់រំផ្ទៃក្នុង សាលានគរបាលជាតិភូមិភាគ សាលានគរបាលជាតិមិត្តភាពកម្ពុជា-វៀតណាម សាស្ត្រាចារ្យនិងគ្រូនគរបាលជាតិ និងមន្ត្រីពាក់ព័ន្ធ ត្រូវផ្សព្វផ្សាយនិងណែនាំបន្តឱ្យបានទូលំទូលាយ ព្រមទាំងអនុវត្តសេចក្តីណែនាំនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។R

ថ្ងៃពុធ ១២រោច ខែភទ្របទឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ដីឥដ្ឋ ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០២៣

ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា

នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យ ឯក មនោសែន

**កន្លែងទទួល៖**

- ថ្នាក់ដឹកនាំបណ្ឌិត្យសភានគរបាលកម្ពុជា
- គ្រប់អង្គភាពពាក់ព័ន្ធចំណុះបណ្ឌិត្យសភានគរបាលកម្ពុជា
- ឯកសារ-កាលប្បវត្តិ